# អនុវិទ្យាល័យបាយ័នបានដំណើរការរយៈពេលបីឆ្នាំ ហើយចាប់ពីពេលនេះតទៅ!!





ឆ្នាំ២០១៥ គឺជាឆ្នាំដ៏ពិសេសសំរាប់JSTចាប់ផ្តើមការងារថ្មី

-ខែតុលា ២០១៥ អនុវិទ្យាល័យបាយ័ន បានបញ្ចប់ការសាងសង់ រួមមាន៖ ថ្នាក់រៀន១៦បន្ទប់ អាគារស្នាក់នៅគ្រូមាន៥បន្ទប់ បង្គន់ ឃ្លាំងដាក់សំភារៈកីឡានិងចង្រ្កាន។ .

-ថ្ងៃទី១ វិច្ឆិកា សាលាអនុវិទ្យាល័យបាយ័ន បានប្រារព្ធពិធីបើកបវេសន្យកាលលើកទី៣ដែលមានសិស្សចូលរៀនចាប់ពីថ្នាក់ទី៧ដល់ទី៩លើកដំបូងសរុបចំនួន៤៦០នាក់។

-ថ្ងៃទី១៦ មករា ២០១៦ ប្រារព្ធពិធីបើកសម្ពោធអនុវិទ្យាល័យបាយ័នអោយប្រើប្រាស់ជាផ្លូវការក្នុងនោះមានការចូលរួមពីសំណាក់ម្ចាស់ជំនួយមកពីប្រទេសជប៉ុន អាមេរិច។

-ថ្ងៃទី១៧ មករា ប្រារព្ធពិធីប្រកួតកីឡាជាលើកដំបូងនៅអនុវិទ្យាល័យបាយ័ន ហើយជាថ្ងៃមួយដែលមានមនុស្សក្នុងតំបន់ច្រើននាក់បានចូលរួមលេងសប្បាយជាមួយគ្នា ។

មុនពេលបង្កើតសាលាអនុវិទ្យាល័យបាយ័នអត្រាសិស្សបន្តចូលរៀនអនុវិទ្យាល័យគឺតិតជាង ១៥% ប៉ុន្តែក្រោយពេលបង្កើតអនុវិទ្យាល័យនេះ អត្រាចូលរៀនកើនដល់១០០% ហើយក្តីស្រមៃរបស់សិស្សដែលមានបំណង ចង់បន្តការសិក្សាបន្ទាប់ពីបញ្ចប់បឋមសិក្សាក្នុងតំបន់បានក្លាយជាការពិត។ ប៉ុន្តែក្នុងតំបន់នេះក៏នូវតែមានបញ្ហាធ្ងន់ធ្ងរក្នុងវិស័យអប់រំផងដែរដូចជា៖

១ សិស្សដែលកំពុងសិក្សានៅបឋមសិក្សាក្នុងតំបន់ចំនួន៥កន្លែង ជួបប្រទះនឹងការរៀនត្រួតថ្នាក់ និងការបោះបង់ការសិក្សា( សូមមើលទិន្នន័យខាងស្តាំ )គ្រប់សាលាអត្រាចូលរៀនរៀងរាល់ឆ្នាំមានចំនួនដូចគ្នា ប៉ុន្តែរហូតដល់ថ្នាក់ទី៦សល់ត្រឹមតែពាក់កណ្តាលប៉ុណ្ណោះ ។

២ នៅតែមានសិស្សបោះបង់ការសិក្សាដើម្បីទៅរកងារធ្វើ ទោះបីជាបានមកសិក្សានៅអនុវិទ្យាល័យបាយ័នក៏ដោយ។ (បច្ចុប្បន្នមានចំនួន១៨ នាក់)

៣ មិនបានបន្តការសិក្សា ព្រោះតែមិនមានវិទ្យាល័យនៅជិត ។

៤ ក្នុងករណីសិស្សមិនបោះបង់ការសិក្សាហើយត្រូវបន្តមកអនុវិទ្យាល័យនោះ អនុវិទ្យាល័យបាយ័ននឹងជួបប្រទះបញ្ហាកង្វះថ្នាក់រៀន( មើលទិន្នន័យខាងស្តាំ ) បើតាមការស្រង់ទិន្នន័យសិស្សដែលត្រូវមករៀននៅអនុវិទ្យាល័យក្នុង ៣ឆ្នាំ មានចំនួនច្រើនជាង ១,000 នាក់។

៥ ការចំណាយលើវិស័យអប់រំដែលទទួលបានពីរដ្ឋគឺ១.៥ដុល្លារសម្រាប់សិស្សមួយនាក់ ដោយសារចំនួននេះតិតតួចពេកដូច្នោះហើយសាលាត្រូវគិតពីការរកចំណូលផ្សេងៗទៀត។

៦ ដោយសារប្រាក់បៀវត្សគ្រូដែលទទួលបានពីរដ្ឋទាបពេក ទើបត្រូវបន្តផ្តល់ប្រាក់ឧបត្ថម្ភលើការធ្វើដំណើររបស់គ្រូជារៀងរាល់ខែ។

បច្ចុប្បន្នសិស្សនៅអនុវិទ្យាល័យបាយ័នមានបំណងចង់បន្តការសិក្សានៅវិទ្យាល័យទាំងអស់គ្នា ដូច្នេះហើយនេះជាគោលដៅបន្ទាប់របស់ JST ដើម្បីសំរេចបំណងពួកគេ និងបន្តឧបត្ថម្ភលើវិស័យអប់រំឲ្យកាន់តែរីកវាលដុះដាលឡើងថែមទៀត ។

■Number of students of 5 elementary schools in Bayon Junior High School district

| Name of School | 1st grade | 2st grade | 3st grade | 4st grade | 5st grade | 6st grade | Total |
|---|---|---|---|---|---|---|---|
| **Angkor Krau** | 164 | 137 | 98 | 85 | 81 | 67 | **632** |
| **Kok Bein** | 42 | 38 | 30 | 33 | 30 | 21 | **194** |
| **Kok Tanao** | 80 | 80 | 82 | 80 | 55 | 43 | **420** |
| **Kok rur** | 27 | 18 | 11 | 13 | 27 | 17 | **113** |
| **Prasat Chat** | 46 | 46 | 38 | 38 | 37 | 38 | **243** |
| Total | **359** | **319** | **259** | **249** | **230** | **186** | **1602** |





**Check the JST and school activities on Facebook!**

★ **JST Facebook**
⇒ https://www.facebook.com/NGO.JST

★ **Bayon junor high school Faebook**
⇒ https://www.facebook.com/bayon.secondaryschool

## គម្រោងជួសជុលចម្លាក់តោនិងនាគនៅប្រាសាទបាយ័ន

### បានបញ្ចប់ការជួសជុលបង្កាន់ដៃ និងចម្លាក់ផ្នែកខាងមុខប្រាសាទបាយ័នហើយ!

គម្រោងនេះបានចាប់ផ្តើមនៅឆ្នាំ2012 បច្ចុប្បន្នបានដំណើរការណ៍ជួសជុលបង្កាន់ដៃ និងចម្លាក់តោ នាគ នៅរោងទងខាងក្រៅចាប់ពីមុខប្រាសាទបាយ័នរហូតដល់ផ្នែកខាងត្បូង។ ថ្មទាំងនេះធ្លាប់បានជួសជុលដោយបារាំងពីសម័យមុន ហើយភាគច្រើនបានបែកបាក់ជាថ្មីម្តងទៀត។ បង្កាន់ដៃនិងចម្លាក់ដែលបានធ្លាក់បែកបាក់ទាំងនោះ បានបែកខ្ទេកពាសវាលពាសកាល ហើយគ្មានសោភណ្ឌ័ភាពនិងអសុវត្ថិភាពខ្លាំងណាស់។ ការងារជួសជុសលើកនេះ ត្រូវជួសជុលថ្មនីមួយៗ ហើយរៀបផ្គុំដាក់ជាថ្មីម្តងទៀតអោយមានលំនឹង ទើបរក្សាបាននូវសុវត្ថិភាពដល់ភ្ញៀវទេសចរណ៍ ហើយធ្វើអោយមានសោភណ្ឌ័ភាពល្អប្រសើរឡើងវិញ។ ម៉្យាងទៀតស្របពេលនឹងការងារជួសជុលយើងនៅតែបន្តផ្ទេរបច្ចេកទេសទៅមនុស្សសម័យក្រោយ «ពីជនជាតិកម្ពុជា ទៅជនជាតិកម្ពុជា» ដោយអ្នកជំនាញដែលមានចំនេះដឹងព្រោះពួកគាត់ឆ្លងកាត់ការសិក្សាស្រាវជ្រាវ និងការអនុវត្តការងារអស់រយៈពេលជិត ២០ឆ្នាំនៅJASA។

តាមរយៈការបង្ហាត់បង្រៀនពីបច្ចេកទេសនិងការងារជួសជុលយ៉ាងយកចិត្តទុកដាក់នៅក្រោមកំដៅថ្ងៃក្តៅខ្លាំងជារៀងរាល់ថ្ងៃ ទើបសមាជិក៧នាក់នៃគម្រោងនេះមានជំហររឹងមាំអាចជឿទុកចិត្តបាន។

※គម្រោងនេះត្រូវបានបន្តក្រោមកិច្ចសហការគ្នាជាមួយសហគមន៍UNESCOជប៉ុន ក្រោមការបង្ហាត់បង្រៀន បច្ចេកទេសពីJASA(ក្រុមរដ្ឋាភិបាលជប៉ុន-អាជ្ញាធរអប្សរា ដើម្បីថែរក្សាប្រាសាទអង្គរ)។

ខែ4 ឆ្នាំ2016 យើងបានចាប់ផ្តើមដំណើរការណ៍គម្រោងទី3ជាបន្តបន្ទាប់ !
គ្រប់សកម្មភាពទាំងអស់មានបង្ហាញក្នុងWEB LOG  សូមទស្សនាកុំខាន!







ផ្នែកជួសជុលរួច



1st phase : 9.2012-3.2014
2nd phase : 4.2014-3.2016

ចម្លាក់នាគ:24 នាគ
ចម្លាក់តោ:13 តោ
បង្កាន់ដៃ:410 កន្លែង

# JST ជាអង្គការដែលឧបត្ថម្ភគាំទ្រដល់ ប្រជាជន ដែលកំពុងរស់នៅជាមួយ សម្បត្តិបេតិកភណ្ឌ

ទំនាក់ទំនងរវាងអ្នកភូមិទាំងអស់ជាមួយនឹងកម្មកររស់នៅភូមិនគរក្រៅ ដែលមកធ្វើការ នៅការដ្ឋានជួសជុលប្រាសាទ រួមជាមួយអ្នកឯកទេសជនជាតិជប៉ុនដែលត្រូវបានគេបញ្ជូន មកធ្វើការងារជួសជុលប្រាសាទក្នុងតំបន់អង្គរ បានចាប់ផ្តើមកកើតមានឡើងនៅឆ្នាំ១៩៩៤ មក។ នៅឆ្នាំ២០០៥ អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកដែលមានឈ្មោះថា JST បានចាប់កំណើតលេចជារូបរាងឡើង។ ពិតជាមានភាពល្អប្រសើរខ្លាំងណាស់ ប្រសិនបើអង្គការ JST អាចស្ថិតនៅក្នុងឋានៈជាកន្លែងប្រមូលផ្តុំ សម្រាប់មនុស្សម្នាទាំងឡាយ រួមមានដូចជាភ្ញៀវទេសចរបរទេសដែលមកទស្សនាប្រាសាទ អ្នកភូមិដែលធ្វើការនៅតាមប្រាសាទ រួមទាំងភ្ញៀវបរទេសដែលជាប់ចិត្តស្រឡាញ់បរិយាកាសនិងប្រវិត្តសាស្រ្តកម្ពុជា មកជួបជុំគ្នាដើម្បីស្វែងយល់ និងសិក្សាអំពីប្រាង្គប្រាសាទបុរាណ។







**តំបន់អនុវត្តន៍ការងារដ៏សំខាន់របស់JST**

JST NEWS

## ភាពយន្តខ្លី « សេចក្តីអំណរគុណពីអនុវិទ្យាល័យបាយ័ន»

ពិធីបើកសម្ពោធអនុវិទ្យាល័យបាយ័នបានបើកជាផ្លូវការដោយមានការចូលរួមពីម្ចាស់ជំនួយជាច្រើនដែលបានបន្តការឧបត្ថមរហូតមកដល់ពេលនេះ។
ទស្សនាតាមURLខាងក្រោម!

**http://y2u.be/-9C0aLPkANo**

※ភាពយន្តខ្លីនេះផលិតឡើងដោយនិស្សិតស្ម័គ្រចិត្តអង្គការ JST ដែលមកពីមហាវិទ្យាល័យ KWANSEIGAKUIN ។



## ~ រួមកម្លាំងរបស់អ្នកដើម្បីអនាគតប្រទេសកម្ពុជា ~

ថវិការឧបត្ថម្ភរបស់អ្នកបានទៅដល់កុមារកម្ពុជាក្នុងរូបភាពដូចខាងក្រោមនេះ!

- ផ្តល់អាហារូបត្ថម្ភដល់ក្មេងៗនៅក្នុងភូមិ
- ផ្តល់ថវិការបន្ថែមដល់គ្រូបង្រៀន(ចេញថ្លៃធ្វើដំណើរ)
- ចំណាយលើការផ្តល់សម្ភារៈសិក្សាទៅដល់សិស្ស
- សកម្មភាពអប់រំកាយ សិល្បៈ និងតន្រ្តី
- ចំណាយលើការថែទាំ និងសម្ភារៈបរិក្ខាររបស់សាលារៀន
- ចំណាយលើ<ទស្សនកិច្ចសិក្សាពីប្រាសាទតំបន់អង្គរសម្រាប់កុមារ>

## អាស័យដ្ឋានទំនាក់ទំនងអង្គការ JST


JST HP：http://www.jst-cambodia.net
Email ：info@jst-cambodia.net

**ទីស្នាក់ការកណ្តាលនៃអង្គការ JST នៅកម្ពុជា** （JASA/UNESCO OFFICE）
អាស័យដ្ឋាន:#056,ក្រុមទី6, ភូមិត្រពាំងសេះ, ឃុំគោកចក, ស្រុកសៀមរាប
ប្រធាន:ជា ណុល
TEL: 097-6710888


**■ ការចូលរួមជាអ្នកស្ម័គ្រចិត្ត ឬជានិស្សិតចុះស្រាវជ្រាវ**

អង្គការ JST កំពុងទទួលស្វាគមន៍ចំពោះនិស្សិតចុះស្រាវជ្រាវ សម្រាប់រយៈពេលខ្លី និងរយៈពេលវែង។ ចំពោះអ្នកមានចំណាប់អារម្មណ៍សូមចូលទៅក្នុង គេហទំព័រ !

**រាល់ការផ្ទេរប្រាក់មូលនិធិ សូមប្រើប្រាស់លេខគណនីខាងក្រោម**

PHNOM PENH COMMERCIAL BANK ,Siem Reap Branch
Bank account；JST　　Account number；115-02-039007-7
Swift Code；PPCBKHPP

## ក្រុមគាំទ្រអង្គការ JST

Special support：**Japan-Apsara Safeguarding Angkor(JASA)**, National Federation of UNESCO Association in Japan(NFUAJ), Café Moi Moi

Angkor Yamanami Fund
International Development Center of Japan(IDCJ)
NPO OASIS International
KOTA Circuit YRP Kiriyama
Nagoya Research Institute of WA-Links for Future Development
KINAN UNESCO Association
Together To the Future(TTF)
KWANSEI GAKUIN University, High School
Seishin Joshi Gakuin High School
Aichi Ichinomiya Commercial High School
Tanabe Technical High School
Kamishima High School
Aichi University of Education
Collins Yamane Sensei fundation
Recycling Organization
Meisei University, BUKAS
NPO Furusato Minami Sinsyu, Midorino Kikin
Kota-cho, Nukata-gun, Aichi
Sanson Ryugaku, Sodateru Kai
Panasonic Corporation
KDDI Co., Ltd.
MITA & Co., Ltd.
UDS Co., Ltd.
Toushou Co., Ltd.
Rotary Club of Honolulu, Tokyo Shimbashi, Tokyo Rainbow, Kyoto, Ichinomiya Chuou, and Ninohe

